**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្តាល

*សំណុំរឿងព្រហ្មទណ្ឌ*
លេខ: ២០០២ អក
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០
ជំនុំជម្រះលេខ៖៤៩៤ ជ.រចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១
សាលក្រមលេខ:៨៧(ប)
ចុះថ្ងៃទី ១៨ ខែ ឧសភា ២០២១

# នាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល
**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ដោយមានសមាសភាព៖**

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## ដើម្បីជំនុំជម្រះ

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ២០០២ អ.កចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមាន៖**

- ឈ្មោះ [redacted] សុខហៀង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ កំរិតវប្បធម៌ថ្នាក់ទី ០៥ មានទីកន្លែងកំណើតនិងទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ហង់ (រស់) ម្តាយឈ្មោះ [redacted] សោភ័យ (រស់) នៅលើវ ជាអនីតិជន ទោសពីមុនគ្មាន ។

(ឃាត់ខ្លួនថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២០ ឃុំខ្លួនតាមដីកាលេខ៖ ៤៦៥៥ ដកបឃខ/២០ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល)។

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) ប្រព្រឹត្តនៅភូមិព្រែកស្វាយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ទិត្យ វិចិត្រ ភេទប្រុសអាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រទុយោ ទីលំនៅភូមិព្រៃកស្វាយ ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្ដាល។

-បានឃើញ របាយការណ៍លេខ៖ ២០២ របក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២០ របស់អធិការដ្ឋាននគរបាលស្រុកស្អាង នៃស្នងការនគរបាលខេត្តកណ្ដាល។

-បានឃើញ សន្និដ្ឋានស្ថាពរលេខ៖ ៤៨៨ ដកសព ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាដំណោះស្រាយលេខ៖ ៥៣២ ដក.ដស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង៣០នាទី រសៀល មានករណី ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ករណីមិនរាងចាល) កើតឡើងនៅចំណុចភូមិព្រៃកស្វាយ ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្ដាល បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខហៀង ភេទប្រុស អាយុ១៧ឆ្នាំ បានត្រឡប់ពីបានជក់ថ្នាំញៀននិងមានភាពស្រវឹងស្រាវិញ ក៏បានទាស់ពាក្យសំដីជាមួយកូនប្រុសជនរងគ្រោះ ហើយជនរងគ្រោះឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ៤៩ឆ្នាំ បានចូលទៅឃាត់កុំឲ្យឈ្លោះប្រកែកគ្នា ប៉ុន្តែបែរជាទាស់សំដីជាមួយជនសង្ស័យបន្ថែមទៀត ពេលនោះជនសង្ស័យខឹងក៏រើសដុំថ្មគប់ទៅលើជនរងគ្រោះ ចំថ្ងាស់បណ្ដាលឲ្យរបួសបែកថ្ងាសហូរឈាម ។ក្រោយកើតហេតុឪពុករបស់ជនសង្ស័យបានចាប់ជនសង្ស័យចង ប្រគល់ឲ្យសមត្ថកិច្ចរួមទាំងវត្ថុតាងមកអធិការដ្ឋាននគរបាលស្រុកស្អាង ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្ដង។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] សុខហៀង បានឆ្លើយថា៖ ថ្ងៃកើតហេតុខ្លួនបានយកដុំថ្មគប់ចំឈ្មោះ [redacted] វិចិត្រ ពីមុខ១ដុំថ្មបណ្ដាលឲ្យឈាម ។ការទាស់គ្នាជាមួយកូនរបស់ឈ្មោះ [redacted] វិចិត្រ តែឈ្មោះ [redacted] វិចិត្រ កាន់ជើងកូនខ្លួនខឹងក៏រើសដុំថ្មគប់ទៅលើឈ្មោះ [redacted] វិចិត្រ តែម្ដង។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនកន្លះឆ្នាំហើយប្រភេទម៉ាទឹកកក ខ្លួនមិនដែលមានទំនាស់ជាមួយជនរងគ្រោះទេ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ បានឆ្លើយថា៖កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០២ និង៣០នាទី រសៀល ខ្លួនបានចេញពីធ្វើការរោងចក្រ មកដល់ផ្ទះឃើញកូនប្រុសខ្លួនឈ្មោះ [redacted] រ៉ាអ៊ី ជើងឯងចឺបានប្រឡាក់ភក់ចឹង កូនខ្លួនបានឆ្លើយប្រាប់ថាឈ្មោះ [redacted] សុខហៀង យកកាំបិតផ្គាក់ដេញកាប់ខ្លួនរត់ធ្លាក់ភក់ ពេលខ្លួនកំពុងសួរកូនស្រាប់តែឈ្មោះ [redacted] សុខហៀង យកកាំបិតផ្គាក់រត់ស្ទុះចូលមកដេញកាប់ខ្លួនដល់ក្នុងផ្ទះរួចខ្លួនក៏បានរត់ទៅយកប៉ែលដើម្បីមកការពារខ្លួន រួចឈ្មោះ [redacted] សុខហៀង បានរត់ចេញបាត់ទៅក្រៅវិញទៅ។ ក្រោយមកបន្តិចស្រាប់តែវារត់មកផ្ទះខ្លួនម្ដងទៀត ហើយយកដុំថ្មធំល្មមគប់មកលើខ្លួនត្រូវចំថ្ងាសបណ្ដាលឲ្យមានរបួសតែម្ដង។

សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ៖នៅក្នុងរឿងនេះតំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកដដែល។ នៅថ្ងៃកើតហេតុជនជាប់ចោទបានច្រៀងឡូឡាដល់អ្នកជិតខាង ជាហេតុបណ្ដាលឲ្យរឿងកើតឡើង។ជនជាប់ចោទធ្លាប់ឪពុកអាណាព្យាបាលយកទៅមណ្ឌលកែប្រែគ្រឿងញៀន។



Scanned with CamScanner

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទស្នើសុំឱ្យតុលាការ៖តាមការសួរដេញដោលលើជនជាប់ចោទគឺអត់មានបទហិង្សាទេ។ ទាក់ទងការប្រើប្រាស់គ្រឿងញៀនករណីមិនរាងចាលគឺអត់មានទេ ការប្រើប្រាស់គ្រឿងញៀនដោយសារមានការអូសទាញពីមិត្តភក្រ្ត័ ហើយកន្លមកកូនក្តីខ្លួនពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីបទគ្រឿងញៀនទេ។

-សំដីចុងក្រោយរបស់ជនជាប់ចោទសុំតុលាការជួយបន្ធូបន្ថយទោសផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

**ក្រោយពីបានពិភាក្សា ក្រុមប្រឹក្សារួចមក**

**<u>សំអាងហេតុ</u>**

១.តុលាកាទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោ [redacted] សុខហៀង ពីបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (មិនរាងចាល)** តាមដីកាដំណោះស្រាយលេខ៖ ៥៣៣២ ដក.ដស/២១ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាលតុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទយោងតាមមាត្រា **២៨៩** មាត្រា **២៩១** និងមាត្រា **៣៥៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច,ចម្លើយជនជាប់ចោទ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា៖ នៅថ្ងៃកើតហេតុ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ជនជាប់ចោទពិតជាបានប្រើប្រាស់ថ្នាំញៀន ករណីមិនរាងចាល និង ប្រព្រឹត្តអំពើហិង្សាដោយយកដុំថ្មគប់ទៅលើជនរងគ្រោះចំថ្ងាបណ្តាលឱ្យបែកក្បាលរបួសហូរឈាម ពិតប្រាកដមែន អំពើរបស់ជនជាប់ចោទរូបនេះ គឺជាអង្គហេតុត្រូវនឹងធាតុផ្សំបទល្មើស **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (មិនរាងចាល)** ដែលមានចែងក្នុងបញ្ញត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥ កថាខណ្ឌទី២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ជនជាប់ចោទឈ្មោះ [redacted] សុខហៀង ជានីតិជន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៤.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុខហៀង ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (មិនរាងចាល) ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះគឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៥.សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំលើកលែងចោទប្រកាន់លើជនជាប់ចោទមានឈ្មោះ [redacted] សុខហៀង គឺពុំត្រឹមត្រូវទេ។



Scanned with CamScanner

៦.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខហៀង ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន(មិនរាងចាល) ប្រព្រឹត្តនៅភូមិព្រែកស្វាយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥ កថាខណ្ឌទី២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧.**អំពើដែលជនជាប់ចោទឈ្មោះ** [redacted] **សុខហៀង** បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈនិងសន្តិសុខសង្គម ធ្វើឱ្យជនរងគ្រោះមានរបួស។ ក៏ប៉ុន្តែជនជាប់ចោទជាអនីតិជន ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណា។

៨-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វិចិត្រ** ពុំប្តឹងទាមទារសំណងអ្វីទេ ចំណុចនេះតុលាការពុំលើកមកពិនិត្យសម្រេចឡើយ។

<u>ហេតុដូច្នេះសម្រេច</u>

-ផ្តន្ទាទោសឈ្មោះ [redacted] សុខហៀង ភេទប្រុស អាយុ១៧ឆ្នាំដាក់ពន្ធនាគារកំណត់រយៈពេល១(មួយ)ឆ្នាំ

**ពីបទ៖ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន(ករណីមិនរាងចាល)** ប្រព្រឹត្តនៅភូមិព្រែកស្វាយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន , មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈថ្ងៃទី១៨ **ខែ ឧសភា ឆ្នាំ២០២១** ចំពោះមុខជនជាប់ចោទ,ចំពោះមុខមេធាវីជនជាប់ចោទ,កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។រក្សាសិទ្ធិប្តឹងទាស់ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៧កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្តាល,ថ្ងៃទី១៨ខែឧសភា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]



Scanned with CamScanner